ibank

# TERMS AND CONDITIONS FOR CAMPAIGN PROGRAM

**Campaign Period:** 24 August — 31 December 2026

**Key Campaign T&C**

- **Eligibility**: **New-to-Bank (NTB)** Individual Customers only. (individual customer never previously held an IBANK account).
- Customer may choose one of the following two bundles:
  - **Bundle 1**: CASA + 12-Month FD or 12-Month iPlan → IBANK Mascot
  - **Bundle 2**: CASA + minimum 10 eligible iBank KH transactions within 30 days → Book & Pen or Umbrella. (Within 30 days after the customer's account opening date).
- **Minimum requirements:**
  - Fixed Deposit (FD): USD 1,000 or KHR equivalent
  - iPlan: USD 100/month or KHR equivalent
  - iBank KH: 10 eligible transactions (Merchant Payment, Virtual Card payment, Phone Top-Up, or Bill Payment)
- **One gift per customer**: Each customer can redeem only one promotional gift during the campaign, regardless of additional qualifying accounts or transactions. (Customers are not permitted to **switch or change** their selected campaign bundle or corresponding gift after selection during the campaign period).
- **Gift availability**: Gifts are distributed first-come, first-served, while stocks last.
- **Gift redemption**:
  - Branch: Receive gift immediately after meeting requirements.
  - E-KYC: Must complete Full KYC at any IBANK branch before receiving the gift.
  - RM: Gift will be delivered/presented by the RM at the next customer visit/appointment.
- **Early account closure:** For this campaign only, any kind of account closed within the first 6 months will be subject to an early closure fee of USD 10, collected over the counter.

- **Early FD withdrawal**: Before maturity, the applicable interest rate will be the prevailing Savings Account interest rate.
- **Other conditions**: All other CASA, FD, and iPlan terms follow the Bank's prevailing product policies.
- **Dispute Resolution:** In the event of any dispute, the Bank will conduct an investigation and provide a response within a reasonable timeframe regarding any issues arising in connection with this incentive program.
- **Amendment Of Terms:** The Bank reserves the right to amend, cancel, or add to these Terms and Conditions without prior notice.
- **Applicable Law:** These Terms and Conditions shall be governed by the laws of the Kingdom of Cambodia.
- **Further Information:** For further information or inquiries regarding this incentive program, please visit the Head Office or the nearest IBANK branch, or contact us via telephone at +855 23/98 901 338 or email at info@ibank.com.kh.
- **Reservation Of Rights:** The Bank reserves the right to amend, suspend, or terminate this incentive program without prior notice, depending on actual circumstances and the allocated budget.
- **Customer Consent:** I have read and agreed to all the Terms and Conditions stated above.

## លក្ខខណ្ឌ និងការកំណត់សម្រាប់កម្មវិធីយុទ្ធនាការ

**រយៈពេលយុទ្ធនាការ**

ថ្ងៃទី 24 ខែសីហា ដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2026

**លក្ខខណ្ឌសំខាន់ៗនៃយុទ្ធនាការ**

- **សិទ្ធិចូលរួម:** អនុវត្តសម្រាប់តែ **អតិថិជនបុគ្គលថ្មីរបស់ធនាគារ (New-to-Bank - NTB) ប៉ុណ្ណោះ(អតិថិជនបុគ្គលដែលមិនធ្លាប់មានគណនីជាមួយ IBANK ពីមុនមក)។**
- **អតិថិជនអាចជ្រើសរើសបាន 1 ក្នុងចំណោម 2 កញ្ចប់៖**
    - **កញ្ចប់ទី 1:** គណនីចរន្ត និងគណនីសន្សំ (CASA) + ប្រាក់បញ្ញើមានកាលកំណត់ 12 ខែ (12-Month FD) ឬ iPlan 12 ខែ → ទទួលបាន **IBANK Mascot**
    - **កញ្ចប់ទី 2:** គណនីចរន្ត និងគណនីសន្សំ (CASA) + ប្រតិបត្តិការតាម iBank KH ដែលមានសិទ្ធិយ៉ាងតិច **10 ប្រតិបត្តិការ ក្នុងរយៈពេល 30 ថ្ងៃ** → ទទួលបាន **សៀវភៅ និងប៊ិច ឬ ធ័ត្រ** តាមជម្រើសរបស់អតិថិជន។ (ក្នុងអំឡុងពេល ៣០ថ្ងៃ ក្រោយកាលបរិច្ឆេទដែលអតិថិជនបើកគណនី)
- **លក្ខខណ្ឌអប្បបរមា៖**
    - **ប្រាក់បញ្ញើមានកាលកំណត់ (Fixed Deposit):** ចំនួន **1,000** ដុល្លារអាមេរិក ឬសមមូលជាប្រាក់រៀល
    - **iPlan:** ចំនួន**ទឹកប្រាក់ 100** ដុល្លារអាមេរិក ឬសមមូលជាប្រាក់រៀល ក្នុងមួយខែ
    - **iBank KH:** យ៉ាងតិច **10 ប្រតិបត្តិការ** ដែលមានសិទ្ធិ រួមមាន ការទូទាត់តាមអាជីវករ (Merchant), ការទូទាត់តាមកាតនិម្មិត(Virtual Card), បញ្ចូលលុយទូរស័ព្ទ (Phone Top-Up) និង ទូទាត់វិក្កយប័ត្រ (Bill Payment)
- **ការទទួលរង្វាន់បានតែ 1 ដងក្នុងម្នាក់:** អតិថិជនម្នាក់អាចទទួលបាន **រង្វាន់តែមួយដង** ក្នុងអំឡុងពេលយុទ្ធនាការទោះបីអតិថិជនមានការបើកគណនីបន្ថែម ឬធ្វើប្រតិបត្តិការបន្ថែមដែលបំពេញលក្ខខណ្ឌក៏ដោយ។ (អតិថិជនមិនត្រូវបានអនុញ្ញាតឱ្យប្តូរ ឬផ្លាស់ប្តូរកញ្ចប់យុទ្ធនាការដែលបានជ្រើសរើស ឬរង្វាន់ដែលពាក់ព័ន្ធនឹងកញ្ចប់នោះឡើយ បន្ទាប់ពីបានជ្រើសរើសរួច ក្នុងអំឡុងពេលយុទ្ធនាការ)។
- **ការផ្តល់រង្វាន់:** រង្វាន់នឹងត្រូវផ្តល់ជូនតាមគោលការណ៍ **មកមុន ទទួលមុន (First-Come, First-Served)** និង អាស្រ័យលើចំនួនរង្វាន់ដែលមានក្នុងស្តុក។
- **ការទទួលរង្វាន់៖**
    - **អតិថិជនតាមសាខា:** ទទួលរង្វាន់ភ្លាមៗ បន្ទាប់ពីបំពេញលក្ខខណ្ឌ។

    - **អតិថិជនតាម** E-KYC: ត្រូវបំពេញ Full KYC **នៅសាខាអាយប៊ែង** (IBANK) **ណាមួយ** មុនពេលទទួលរង្វាន់។

    - **អតិថិជនតាមបុគ្គលិកគ្រប់គ្រងទំនាក់ទំនងអតិថិជន**(Relationship Manager): **បុគ្គលិកគ្រប់គ្រងទំនាក់ទំនងអតិថិជន** (Relationship Manager) នឹងប្រគល់រង្វាន់ជូននៅពេលជួប ឬណាត់ជួបអតិថិជនលើកបន្ទាប់។

- **ការបិទគណនីមុនកំណត់:** សម្រាប់យុទ្ធនាការនេះតែប៉ុណ្ណោះ គណនីគ្រប់ប្រភេទដែលត្រូវបានបិទក្នុងរយៈពេល **6 ខែដំបូង** នឹងត្រូវបង់ **ថ្លៃបិទគណនីមុនកាលកំណត់ចំនួន 10 ដុល្លារអាមេរិក** ដែលត្រូវបង់នៅបញ្ជរធនាគារ (Over the Counter)។

- **ការដកប្រាក់បញ្ញើមានការកំណត់ (Fixed Deposit) មុនកាលកំណត់:** ប្រសិនបើដកប្រាក់**បញ្ញើមានការកំណត់**(Fixed Deposit) មុនថ្ងៃផុតកំណត់ អត្រាការប្រាក់ដែលត្រូវអនុវត្តនឹងជា អត្រាការប្រាក់គណនីសន្សំ (Savings Account) ដែលមានសុពលភាពនៅពេលនោះ។

- **លក្ខខណ្ឌផ្សេងៗ:** លក្ខខណ្ឌផ្សេងទៀតសម្រាប់ គណនីចរន្ត និងគណនីសន្សំ (CASA),**បញ្ញើមានការកំណត់** (FD និង iPlan ត្រូវអនុវត្តតាម **គោលការណ៍ និងលក្ខខណ្ឌផលិតផលរបស់ធនាគារដែលមានសុពលភាព**។

- **ដំណោះស្រាយជម្លោះ:** នៅពេលដែលមានជម្លោះកើតឡើង ធនាគារនឹងធ្វើការស៊ើបអង្កេត និងឆ្លើយតបក្នុងរយៈពេលសមស្រប ចំពោះបញ្ហាណាមួយដែលកើតមានទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ។

- **លក្ខខណ្ឌកែប្រែ:** ធនាគាររក្សាសិទ្ធិក្នុងការកែប្រែ លុបចោល ឬបន្ថែមលក្ខខណ្ឌទាំងនេះដោយគ្មានការជូនដំណឹងទុកជាមុន។

- **ច្បាប់ដែលត្រូវអនុវត្ត:** លក្ខខណ្ឌទាំងនេះត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

- **សម្រាប់ព័ត៌មានបន្ថែម:** សម្រាប់ព័ត៌មានបន្ថែម ឬសំណួរពាក់ព័ន្ធនឹងកម្មវិធីលើកទឹកចិត្តនេះ សូមអញ្ជើញមកកាន់ទីស្នាក់ការកណ្តាល និងសាខារបស់ ធនាគារ អាយប៊ែង ដែលនៅជិតលោកអ្នកបំផុត ឬទំនាក់ទំនងមកកាន់យើងខ្ញុំតាមរយៈលេខទូរស័ព្ទ +855 23/98 901 338 ឬអ៊ីម៉ែល info@ibank.com.kh។

- **ការរក្សាសិទ្ធិរបស់ធនាគារ:** សូមជម្រាបជូនថា ធនាគាររក្សាសិទ្ធិក្នុងការកែប្រែ ផ្អាក ឬបញ្ចប់កម្មវិធីលើកទឹកចិត្តនេះ ដោយពុំចាំបាច់ជូនដំណឹងជាមុន អាស្រ័យលើស្ថានភាពជាក់ស្តែង និងកញ្ចប់ថវិកាដែលបានកំណត់។

- **ការបញ្ជាក់យល់ព្រមពីអតិថិជន:** ខ្ញុំបានអាន និងយល់ព្រមតាមលក្ខខណ្ឌទាំងអស់ដែលមានចែងខាងលើ។